Australian Government

# Fair Work OMBUDSMAN

# ជំនួយភាសា

ច្បាប់ទំនាក់ទំនងកន្លែងធ្វើការរបស់ប្រទេសអូស្ត្រាលីធ្វើការផ្លាស់ប្ដូរចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2009 ។

ច្បាប់ថ្មីនេះពណ៌នានូវសិទ្ធិនិងកាតព្វកិច្ចទាំងឡាយដែលពលរដ្ឋមាននៅឯកន្លែងធ្វើការ។

ការផ្លាស់ប្ដូរទាំងនេះមានផលប៉ះពាល់ដល់កន្លែងធ្វើការអូស្ត្រាលីភាគច្រើន។

សិទ្ធិនិងកាតព្វកិច្ចទាំងនេះ ខ្លះគឺអំពី៖

- ចំនួនប្រាក់ដែលនិយោជិតគួរទទួល
- សិទ្ធិទទួលការឈប់សម្រាកនិងលក្ខខណ្ឌការងារ
- កំណត់ត្រាដែលនិយោជកត្រូវការរក្សាទុក
- របៀបដែលនិយោជិតនិងនិយោជកអាចទទួលជំនួយបើគេមានបញ្ហានៅកន្លែងធ្វើការ
- គ្មានការរើសអើង ឧទាហរណ៍៖ ដោយសារតែមូលហេតុជាតិពន្ធ ភេទ ចំណូលចិត្តនៃការរួមភេទ អាយុ ពិការភាពផ្លូវចិត្តឬរាងកាយ ឬស្ថានភាពនៅលីវឬមានគូស្រករហើយ។

## នរណាអាចជួយបាន?

មានអង្គការពីរនៅក្នុងប្រព័ន្ធថ្មីនៃទំនាក់ទំនងកន្លែងធ្វើការជាតិ។

អង្គការទាំងពីរនេះគឺ Fair Work Commission និង Fair Work Ombudsman ។

Fair Work Commission គឺជាសាលាក្ដីជាតិខាងផ្នែកទំនាក់ទំនងកន្លែងធ្វើការ។ សាលាក្ដីនេះគឺជាស្ថាប័នឯករាជដែលមានអំណាចអនុវត្តមុខងារមួយចំនួនផ្សេងៗគ្នា ដែលទាក់ទងនឹង៖

- ប្រព័ន្ធសុវត្ថិភាព (safety net) នៃបៀវត្សរ៍ទាបបំផុតនិងលក្ខខណ្ឌការងារ
- ការចរចាសហគ្រាស (enterprise bargaining)
- កូដកម្មឬសកម្មភាពតវ៉ាពាក់ព័ន្ធនឹងការងារ
- ការដោះស្រាយជម្លោះ
- ការបញ្ឈប់ពីការងារ
- បញ្ហាឯទៀតនៅកន្លែងធ្វើការ។

Fair Work Ombudsman:

- ផ្ដល់ឱវាទនិងការអប់រំស្ដីអំពីច្បាប់កន្លែងធ្វើការរបស់ប្រទេសអូស្ត្រាលី
- តាមពិនិត្យនូវការអនុវត្តតាម និងអង្កេតអំពើល្មើសនឹងច្បាប់ជាតិនៅតាមកន្លែងធ្វើការ
- បោះផ្សាយព័ត៌មានអំពីសិទ្ធិនិងកាតព្វកិច្ចនៅកន្លែងធ្វើការ
- ផ្ដល់ឯកសារនិងព័ត៌មានសម្រាប់អាជីវកម្មខ្នាតតូច។

## ត្រូវការព័ត៌មានបន្ថែមឬទេ?

- សូមទាក់ទង Fair Work Infoline តាមទូរសព្ទលេខ 13 13 94 ។
- ដើម្បីទទួលជំនួយបកប្រែភាសា សូមទាក់ទង **សេវាបកប្រែភាសា** (TIS) តាមទូរសព្ទលេខ **131 450** ដោយអស់ថ្លៃសម្រាប់ទូរសព្ទក្នុងតំបន់ ចំនួន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុ

**Fair Work Infoline:** 13 13 94 **www.fairwork.gov.au**

Fair Work Ombusman ប្ដេជ្ញាផ្ដល់លោកអ្នកនូវឱវាទដែលលោកអ្នកអាចទុកចិត្តបាន។
ព័ត៌មានដែលមាននៅក្នុងក្រដាសផ្ដល់ព័ត៌មាននេះគឺជាព័ត៌មានទូទៅ។ ប្រសិនបើលោកអ្នកមិនប្រាកដថាព័ត៌មាននេះអនុវត្តលើស្ថានភាពរបស់លោកអ្នកយ៉ាងម៉េចនោះ លោកអ្នកអាចទូរស័ព្ទទៅខ្សែទូរស័ព្ទផ្ដល់ព័ត៌មានតាមលេខ 13 13 94 ឬនិយាយជាមួយសហជីព, សមាគមឧស្សាហកម្ម ឬអ្នកមានវិជ្ជាជីវៈខាងទំនាក់ទំនងនៅកន្លែងការងារ។

**Last updated:** December 2013
© Copyright Fair Work Ombudsman
FWOFSKH1.02